CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

សង្ខេបសម្រាប់
គោលនយោបាយ

លេខ ០៣ មេសា ២០១៤

# យេនឌ័រ និងអភិបាលកិច្ចទឹក៖ កាត់បន្ថយបញ្ហាប្រឈមចំពោះការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ

*ដោយ ណាំង ភិរុណ និង អ៊ួច ឈួង*

## សារគន្លឹះ

- ស្របតាមគោលនយោបាយ ការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ក៏ដូចជាការអភិវឌ្ឍនិងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយការចូលរួម (PIMD) ស្ត្រីបានចូលរួមយ៉ាងសកម្មតាំងពីយូរមកហើយ ក្នុងការគ្រប់គ្រងទឹក និងប្រព័ន្ធស្រោចស្រព។ ទោះយ៉ាងនេះក្តី ស្ត្រីនៅមានបទពិសោធន៍តូចចង្អៀតជាង និងជំនាញតិចជាងបុរស ហើយការចូលរួមពេញលេញរបស់ពួកគេ បានជួបការរាំងស្ទះដោយសារបន្ទុកធំពីរនៃតួនាទីផលិតកម្មផងនិងបន្តពូជពង្សផង ព្រមទាំងជួបឧបសគ្គជាច្រើនផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌។
- ចំនួនស្ត្រីនៅក្នុងតួនាទីជាអ្នកដឹកនាំ នៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) នៅមានកម្រិតទាប ទោះបីមានសកម្មភាពបញ្ជ្រាបយេនឌ័រ និងលើកកម្ពស់សិទ្ធិអំណាចស្ត្រី នៅកម្រិតមូលដ្ឋានក្តី។ បុរសគ្រប់ដណ្តប់លើតួនាទីសំខាន់ៗបំផុតនៅក្នុងគណៈកម្មាធិការ សកបទ ហើយស្ត្រីកម្រនឹងមានសិទ្ធិអំណាចនៅក្នុងតួនាទី ធ្វើការសម្រេចចិត្តណាស់។ ស្ត្រីក៏មានលទ្ធភាពតូចដែរក្នុងការប្រើប្រាស់ និងត្រួតត្រាលើទ្រព្យធនគ្រួសារ និងធនធានទ្រព្យរួម។
- កសិករទាំងបុរស និងស្ត្រីកំពុងប្រឈមនឹងបញ្ហាកំណើនផលប៉ះពាល់ពាក់ព័ន្ធនឹងអាកាសធាតុ។ អភិបាលកិច្ចទឹកកាន់តែប្រសើរ ការពង្រីកប្រព័ន្ធស្រោចស្រព និងជំនួយទ្រទ្រង់នៅថ្នាក់មូលដ្ឋាន ជាកត្តាសំខាន់សម្រាប់ជួយពួកគេក្នុងការបន្សាំខ្លួន ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងកសាងភាពធន់ក្នុងជីវភាពរស់នៅ។
- កសិករដែលមិនមែនជាសមាជិកសកបទ (ជាពិសេសគ្រួសារមានស្ត្រីជាមេគ្រួសារ) និងកសិករដែលមានស្រែនៅឆ្ងាយពីប្រឡាយ តែងងាយរងគ្រោះជាងគេដោយសារមហន្តរាយផ្សេងៗជាប់ទាក់ទងទៅនឹងអាកាសធាតុ ជាពិសេស ភាពកាន់តែញឹកញាប់ឡើងនៃទឹកជំនន់ និងគ្រោះរាំងស្ងួត។
- ការដាក់បញ្ចូលគោលគំនិតផ្នែកយេនឌ័រ ទៅក្នុងការធ្វើផែនការ និងការអនុវត្តវិធានការ ឆ្លើយតបនឹងបញ្ហាផ្នែកអាកាសធាតុនៅគ្រប់កម្រិត និងគ្រប់វិស័យ មានសារៈសំខាន់ណាស់ ព្រោះវាផ្តល់អំណាចឲ្យស្ត្រី ព្រមទាំងពង្រឹងសិទ្ធិរបស់ពួកគេក៏ដូចជាលទ្ធភាពប្រើប្រាស់ និងត្រួតត្រាលើធនធានដ៏ចាំបាច់សម្រាប់ការកាត់បន្ថយ និងបន្សាំទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។

## បញ្ហាចោទ

រដ្ឋាភិបាលបានដាក់បញ្ចូល IWRM និង PIMD ទៅក្នុងផែនការ និងគោលនយោបាយអភិវឌ្ឍន៍ជាតិ តាំងពីយូរមកហើយ ជាការឆ្លើយតបនឹងតម្រូវការ បង្កើនការចូលរួមឲ្យបានច្រើនបំផុតពីសំណាក់អ្នកពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន ក្នុងការគ្រប់គ្រងទឹក ដើម្បីកែលំអប្រព័ន្ធស្រោចស្រព បង្កើនផលិតកម្មស្រូវ លើកកម្ពស់ជីវភាពរស់នៅ និងកសាងភាពធន់នឹងអាកាសធាតុ (MOWRAM 2005, 2007)។ ទោះជាយ៉ាងនេះក្តី ចំនួនស្ត្រីមានតំណែងក្នុងគណៈកម្មាធិការ សកបទ នៅមានតិចនាក់ ហើយបុរសនៅតែបន្តគ្របដណ្តប់លើគណៈកម្មាធិការ។ ប្រការនេះ ធ្វើឲ្យស្ត្រីមានតួនាទីបន្ទាប់បន្សំ និងអសកម្ម ហើយបានផាត់ពួកគេចេញពីការចូលរួមដោយផ្ទាល់ ក្នុងការគ្រប់គ្រងទឹកស្រោចស្រព និងសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងរារាំងដល់លទ្ធភាពរបស់ពួកគេ ក្នុងការប្រើប្រាស់ និងត្រួតត្រាលើធនធានដ៏ចាំបាច់ៗ សម្រាប់ទប់ទល់នឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

---

លោក ណាំង ភិរុណ ជាអ្នកស្រាវជ្រាវ ហើយលោក អ៊ួច ឈួង ជាជំនួយការកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)។ សូមយោងឯកសារនេះថា: Nang Phirun and Ouch Chhuong (2014), *Gender and Water Governance: Reducing the Challenges to Women's Participation in Irrigation Management in the Context of Climate Change*, Policy Brief No. 03, April 2014 (Phnom Penh: CDRI) www.cdri.org.kh/download.htm

ឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ អាចមើលឃើញច្បាស់ជាស្រេច ហើយនឹងបន្តប៉ះពាល់ខ្លាំង ទៅលើសន្តិសុខទឹក ដំណាំដាំដុះ សត្វចិញ្ចឹម ប្រព័ន្ធអេកូឡូស៊ី ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សុខភាពមនុស្ស និងការតាំងទីលំនៅរបស់មនុស្ស ព្រមទាំងអាយុជីវិតមនុស្សទៀតផង។ ក្នុងបរិបទបែបនេះ ស្ត្រី និងកុមារតែងងាយរងគ្រោះជាងបុរសដោយសារជីវភាពពួកគេមានការពឹងផ្អែកខ្លាំងទៅលើធនធានធម្មជាតិជាង ដូច្នេះវាងាយប៉ះពាល់ដោយគ្រោះធម្មជាតិ។ ស្ត្រី និងកុមារក៏មានទ្រព្យធនតិចជាងដែរសម្រាប់ដោះទាល់, មានលទ្ធភាពតិចជាង ក្នុងការប្រើប្រាស់ ត្រួតត្រាលើធនធានសំខាន់ៗសម្រាប់ការចិញ្ចឹមជីវិត, និងតែងមានរាងកាយទន់ខ្សោយជាង ដូច្នេះហើយក៏ងាយរងគ្រោះជាងគេដោយសារជំងឺឆ្លងផ្សេងៗ (WEN 2010)។ ហេតុនេះ ស្ត្រីទំនងមានសមត្ថភាពបន្សាំខ្លួនទាបជាង ក្នុងការទប់ទល់នឹងគ្រោះអាសន្នផ្នែកអាកាសធាតុ។

## ករណីសិក្សា

ក្រុមស្រាវជ្រាវ បានជ្រើសយកប្រព័ន្ធស្រោចស្រពចំនួន ១០ ក្នុង ៣ខេត្ត គឺខេត្តកំពង់ឆ្នាំង កំពង់ធំ និងពោធិ៍សាត់ សម្រាប់ធ្វើការសិក្សា។ ក្នុងនេះ មានការរៀបចំការពិភាក្សាតាមក្រុមស្នូលចំនួនមួយនៅតាមប្រព័ន្ធនីមួយៗ និងបានធ្វើសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះចំនួន ១១លើក ដោយជ្រើសរើសអ្នកពាក់ព័ន្ធដូចជា ប្រធាន សកបទ, កសិករ, ប្រធានភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ, មន្ត្រីមន្ទីរកិច្ចការនារី, មន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម, មន្ត្រីមន្ទីរបរិស្ថាន, និង មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (សម្រាប់ព័ត៌មានលំអិតផ្សេងៗ សូមមើលនៅក្នុង Nang and Ouch 2014)។

## លទ្ធផលស្រាវជ្រាវ៖ បញ្ហាប្រឈមចំពោះស្ត្រី កង្វះឱកាសសម្រាប់ការចូលរួមសកម្ម

រដ្ឋាភិបាលបានដាក់បញ្ចូលគោលការណ៍ IWRM និង PIMD ទៅក្នុងផែនការនិងគោលនយោបាយជាតិ និងបានកំណត់វិធីសាស្ត្រទាំងនេះថា ជាយុទ្ធសាស្ត្រស្នូល ដើម្បីជំរុញការចូលរួមចំណែកនៅមូលដ្ឋាន ក្នុងការគ្រប់គ្រងទឹកសម្រាប់កសិកម្ម។ ស្ត្រីបានចូលរួមសកម្មនៅក្នុង សកបទ និងបានយល់ដឹងពីបញ្ហានានាជុំវិញអភិបាលកិច្ចទឹកក្នុងពេលបច្ចុប្បន្ន ដូចជា ការកំណត់និងប្រមូលថ្លៃសេវាស្រោចស្រព, ការប្រើប្រាស់ប្រាក់សន្សំរួមគ្នា, និងតម្រូវការថែទាំប្រឡាយនិងទំនប់ទឹក។ មានពេលខ្លះ ស្ត្រីអាចដោះស្រាយបញ្ហាទាំងនេះបានល្អជាងបុរសទៀតផង។ ទោះជាយ៉ាងនេះក្តី ស្ត្រីដែលកាន់កាប់តំណែងដែលមានការទទួលខុសត្រូវ និងសម្រេចចិត្ត នៅក្នុងគណៈកម្មាធិការ សកបទ នៅមានចំនួនតិចនៅឡើយ។

មានកត្តាជាច្រើន ដែលរារាំងដល់ការចូលរួមពេញលេញរបស់ស្ត្រីនៅក្នុងការងារសាធារណៈ និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ជាអាទិ៍ ស្ត្រីត្រូវចំណាយពេលលើការងារច្រើនមុខ។ ក្រៅពីការងារកសិកម្ម និងអាជីវកម្មតាមផ្ទះ ស្ត្រីត្រូវទទួលខុសត្រូវជាចម្បងលើការងារផ្ទះថែមទៀត។ ក្នុងការគ្រប់គ្រងធនធានទឹកក៏មានការងារត្រូវប្រើកម្លាំងជាច្រើន ដែលទាមទារនូវកាយសម្បទាមាំមួន និងភាពអំណត់។ ការចូលរួមពេញលេញ ត្រូវមានការប្តេជ្ញាចិត្ត និងបទពិសោធន៍ក្នុងបញ្ហាពាក់ព័ន្ធដូចជា ការគ្រប់គ្រងទឹក, ការធ្វើកសិកម្ម, ការកសាងហេដ្ឋារចនាសម្ព័ន្ធ, បញ្ហាផ្នែកយេនឌ័រ, ការកាត់បន្ថយ និងគ្រប់គ្រងគ្រោះមហន្តរាយ, និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ជំនាញ និងចំណេះដឹងមានកម្រិតរបស់ស្ត្រីនៅក្នុងបញ្ហាទាំងនេះ អាចជាឧបសគ្គរារាំងដល់ការចូលរួមរបស់ពួកគេ។ ទាំងនេះជាមូលហេតុនាំឲ្យចំនួនស្ត្រីក្នុងមុខតំណែង ធ្វើសេចក្តីសម្រេចចិត្តនៅក្នុងគណៈកម្មាធិការ សកបទ នៅមានចំនួនតិច៖ ក្នុងចំណោមសមាជិកគណៈកម្មាធិការ ៤៣នាក់ នៅក្នុង សកបទ ដែលបានសិក្សាទាំង ១០ គឺមានសមាជិកស្ត្រីតែ ៩នាក់ប៉ុណ្ណោះ។ បុរសកាន់កាប់មុខតំណែងដឹកនាំស្ទើរតែទាំងអស់នៅក្នុង សកបទ។ ពួកគេ ជាអ្នកផ្តល់គំនិតផ្នែកបច្ចេកទេស កាន់កាប់តួនាទីគ្រប់គ្រង និងធ្វើការសម្រេចចិត្តចុងក្រោយ រីឯស្ត្រីភាគច្រើនកាន់តំណែងជាហិរញ្ញិក និងគណនេយ្យករ។ វិសមភាពផ្នែកចំនួន និងទំនាក់ទំនងអំណាច ធ្វើឲ្យស្ត្រីមានតួនាទីបន្ទាប់បន្សំ និងអសកម្ម ព្រមទាំងមិនមានការចូលរួមដោយផ្ទាល់ក្នុងការគ្រប់គ្រងទឹកស្រោចស្រព។

## ភាពងាយរងគ្រោះបំផុត ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

កសិករនៅក្នុងខេត្តសិក្សាទាំងបី បានកត់សំគាល់ឃើញថាពួកគេកំពុងប្រឈមនឹងគ្រោះធម្មជាតិ និងផលប៉ះពាល់ផ្នែកអាកាសធាតុកាន់តែច្រើនឡើង ជាពិសេស ទឹកជំនន់ ខ្យល់ព្យុះ កំណើនសីតុណ្ហភាព ជំងឺឆ្លងតាមសត្វ និងគ្រោះរាំងស្ងួត។ កំណើនសីតុណ្ហភាពនាំឲ្យមានកំណើនចំនួនសត្វល្អិតចង្រៃ ដូចជា ដង្កូវកណ្តូប ដង្កូវនាង និងមមាចត្នោត ដែលអាចបំផ្លាញស្រូវអស់ច្រើនហិកតាក្នុងពេលតែមួយយប់។ ក្រៅពីកាត់បន្ថយការដុះលូតលាស់ និងទិន្នផលដំណាំ កំណើនសីតុណ្ហភាព ក៏មានជាប់ពាក់ព័ន្ធផងដែរនឹងការឈឺថ្កាត់កាន់តែញឹកញាប់ឡើង ជាពិសេសសម្រាប់កុមារ។ ទឹកជំនន់ (បន្ទាប់មកទៀតមាន ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត) គឺជាបញ្ហាអាកាសធាតុធ្ងន់ធ្ងរ បើតាមយោបល់របស់ប្រជាជននៅជនបទ។ កសិកររាយការណ៍ថា បរិមាណ ហ្វ្រេកង់ និងរយៈពេលភ្លៀងធ្លាក់ បានប្រែប្រួលដូចជា រយៈពេលភ្លៀងធ្លាក់ជួនកាលខ្លីពេក ជួនកាលវែងពេក ជួនកាលយឺតយ៉ាវពេក។ តំបន់សិក្សាជាច្រើន ជួបគ្រោះរាំងស្ងួតយ៉ាងយូររហូតដល់មួយខែ ពីរខែ ឬបីខែ ក្នុងឆ្នាំ២០១២ គឺចាប់ពីពាក់កណ្តាលខែឧសភា ដល់ពាក់កណ្តាលខែសីហា។ ដំណាំស្រូវត្រូវបំផ្លិចបំផ្លាញ ឬខូចខាត, ទឹកស្ទឹង និងអូរចាប់ផ្តើមរីងស្ងួត ហើយស្មៅ (សម្រាប់ចិញ្ចឹមសត្វ) ត្រូវស្វិតក្រៀមអស់។ គ្រោះរាំងស្ងួត ក៏បង្កបញ្ហាធ្ងន់ធ្ងរដល់ប្រជាជន

ដែលរស់នៅឆ្ងាយពីប្រព័ន្ធស្រោចស្រពផងដែរ ព្រោះទឹកនៅក្នុងប្រឡាយឬប្រព័ន្ធដោះទឹក មានមិនគ្រប់គ្រាន់ឡើយ។ កសិករត្រូវចំណាយទុនអស់ច្រើនលើការបូមទឹក (ថ្លៃឈ្នួលបូម និងថ្លៃម៉ាស៊ូត) សម្រាប់ស្រោចស្រពស្រែចំការរបស់ខ្លួន ហើយកសិករមួយចំនួនមិនមានឧបករណ៍សមស្របទេ ដែលនាំឲ្យស្រូវរបស់គាត់ត្រូវរងការខូចខាត។ ប្រជាជនក្រីក្រ កុមារ ស្ត្រីមេម៉ាយ និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ជាក្រុមងាយរងគ្រោះជាងគេ។ ការសង្កេតពិនិត្យដល់កន្លែងបង្ហាញថា គ្រោះធម្មជាតិជះឥទ្ធិពលទៅលើបុរស និងស្ត្រីស្ទើរតែដូចគ្នា។ ប៉ុន្តែស្ត្រីមានសមត្ថភាពទាបជាងបុរស ក្នុងការទប់ទល់នឹងផលប៉ះពាល់ខ្លះនៃការប្រែប្រួលអាកាសធាតុ ជាពិសេស បញ្ហាកំណើនសីតុណ្ហភាព។

## កត្តាជះឥទ្ធិពលលើលទ្ធភាពប្រើប្រាស់ធនធានចិញ្ចឹមជីវិតសំខាន់។

ទិន្នន័យរកឃើញជាក់ស្តែងបង្ហាញថា លទ្ធភាពប្រើប្រាស់ និងត្រួតត្រាលើធនធានចិញ្ចឹមជីវិត (ធនធានមនុស្ស, ធម្មជាតិ, រូបវ័ន្ត, ហិរញ្ញវត្ថុ និងសង្គម) ជាគន្លឹះក្នុងការទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ តួយ៉ាង ធនធានហិរញ្ញវត្ថុជាតម្រូវការមួយសម្រាប់ការអភិវឌ្ឍ គ្រប់គ្រង និងថែទាំប្រព័ន្ធស្រោចស្រព អាងស្តុកទឹក ទំនប់ការពារទឹកជំនន់ និងហេដ្ឋារចនាសម្ព័ន្ធជនបទ។ ធនធានមនុស្សក៏ត្រូវតែមានដែរ សម្រាប់ផ្តល់ការណែនាំ និងជំនួយទ្រទ្រង់ផ្នែកបច្ចេកទេស ឲ្យបានទាន់ពេល និងចំគោលដៅ។ ធនធានមនុស្សចាំបាច់ណាស់សម្រាប់ធ្វើការពិនិត្យតាមដាន និងបង្កើនការយល់ដឹងរបស់ស្ត្រី អំពីបញ្ហាពាក់ព័ន្ធផ្សេងៗ, ជំរុញការចូលរួម និងភាពជាតំណាងរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត, និងកសាងសមត្ថភាពនិងភាពធន់របស់ស្ត្រី។ សហគមន៍ និងអាជ្ញាធរមូលដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយទ្រទ្រង់ឲ្យស្ត្រីចេះប្រើប្រាស់សិទ្ធិ និងពង្រីកតួនាទីរបស់ខ្លួន។

នៅថ្នាក់ក្រោមជាតិ បណ្តាមន្ទីរជំនាញថ្នាក់ខេត្ត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ កាកបាទក្រហមកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល បណ្តាញស្ត្រី អ្នកស្ម័គ្រចិត្ត និងក្រុមជួយស្ត្រីក្នុងភូមិ ឬសហគមន៍ កំពុងផ្តល់ការទ្រទ្រង់យ៉ាងសកម្មដល់ប្រជាជនដែលត្រូវប្រឈមមុខនឹងគ្រោះមហន្តរាយ ពាក់ព័ន្ធនឹងអាកាសធាតុ។ ជំនួយទ្រទ្រង់ទាំងនេះមានដូចជា ការកំណត់រកទីតាំងមានសុវត្ថិភាពសម្រាប់ការជម្លៀសប្រជាជន, ការផ្តល់គ្រាប់ពូជ និងជី, ការបណ្តុះបណ្តាល និងការបង្ហាត់បង្ហាញផ្ទាល់ដល់កន្លែង ដើម្បីជួយកសិករឲ្យងើបផុតពីគ្រោះភ័យមកវិញ។ បុរស ស្ត្រី និងក្រុមទន់ខ្សោយទាំងឡាយ មានសិទ្ធិស្មើគ្នាក្នុងការទទួលបានសេវាកម្មនេះ។ ទោះយ៉ាងនេះក្តី ទីតាំងភូមិសាស្ត្រ និងកង្វះប្រព័ន្ធស្រោចស្រព ធ្វើឲ្យកសិករមិនអាចទទួលបានការផ្គត់ផ្គង់ទឹកទៀងទាត់ល្អសម្រាប់ស្រោចស្រពដំណាំ ហើយបញ្ហាកង្វះទឹកក៏ផុសឡើង។ ការខ្សត់ទឹកនាំឲ្យមានទំនាស់ក្នុងការប្រើប្រាស់ទឹក និងការខូចខាតផលដំណាំ។ នៅក្នុងគម្រោងសិក្សាមួយចំនួន ស្ត្រីក្រីក្រនិងគ្រួសារដែលមានស្ត្រីជាមេគ្រួសារជាច្រើនដែលមានដីស្រែនៅឆ្ងាយពីប្រឡាយមេ មិនអាចទប់ទល់នឹងគ្រោះធម្មជាតិបានទេ ទោះបីជាមានយន្តការជួយទ្រទ្រង់ដូចខាងលើក្តី។ ជាទូទៅពួកគេមានដីស្រែតូចៗណាស់ ហើយខ្វះទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ។ ទោះបីជាមានយន្តការជំរុញការបញ្ជ្រាបយេនឌ័រ និងការផ្តល់សិទ្ធិអំណាចឲ្យស្ត្រីក្តី (យន្តការខ្លះអនុវត្តដោយស្ថាប័នរដ្ឋ ក្រុមការងារសង្គមនៅមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល) ក៏ចំណេះដឹង (ជាពិសេស របស់ស្ត្រី) និងរបៀបរបបក្នុងសង្គម និងវប្បធម៌ នៅតែរាំងដល់ដំណើរការបញ្ជ្រាបយេនឌ័រ និងការផ្តល់សិទ្ធិអំណាចឲ្យស្ត្រីនៅតំបន់ជនបទ។

## អនុសាសន៍

អនុសាសន៍ដូចខាងក្រោម សំដៅផ្តល់ជូនស្ថាប័នពាក់ព័ន្ធទាំងអស់ អាជ្ញាធរនិងសហគមន៍មូលដ្ឋាន អ្នកគ្រប់គ្រងនិងអ្នកអនុវត្ត ដៃគូអភិវឌ្ឍន៍ និងអ្នកសិក្សាស្រាវជ្រាវនានា នូវគោលគំនិតមួយចំនួនសម្រាប់យកទៅពិចារណាបន្ថែម ដើម្បីជួយកំណត់នូវទិសដៅគោលនយោបាយ និងសកម្មភាពនាពេលអនាគត ហើយឈានទៅដោះស្រាយបញ្ហានានាដែលស្ត្រីកំពុងប្រឈមមុខ។

## កាត់បន្ថយបញ្ហាប្រឈមរបស់ស្ត្រី

- ត្រូវពង្រឹងសមត្ថភាពស្ត្រីតាមរយៈ សកបទ និងក្រុមការងារសង្គមផ្សេងទៀត ដោយអនុវត្តតាមគោលការណ៍ IWRM និង PIMD និងក្របខ័ណ្ឌបន្សាំផ្អែកលើសហគមន៍ ព្រមទាំងត្រួតពិនិត្យ/កែទម្រង់ច្បាប់ដែលមានស្រាប់ (បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ លក្ខណៈវិនិច្ឆ័យនៃការបោះឆ្នោត) និងបទបញ្ញត្តិផ្សេងទៀត ដែលអាចរាំងស្ទះដល់ការចូលរួមរបស់ស្ត្រី ឬភាពជាតំណាងរបស់ពួកគេ។
- ធានាថា គោលនយោបាយ និងគម្រោងឬកម្មវិធីអភិវឌ្ឍន៍ថ្មីៗមានគិតគូរពីភាពខុសប្លែកគ្នាជាក់លាក់ផ្នែកយេនឌ័រ និងជំរុញការចូលរួមសកម្មរបស់ស្ត្រីនៅគ្រប់កម្រិត។
- ពង្រឹងអភិបាលកិច្ចទឹក ដោយដោះស្រាយនូវទិដ្ឋភាពសេដ្ឋកិច្ចសង្គម យេនឌ័រ បរិស្ថាន និងគោលនយោបាយ ដើម្បីធានាថាធនធានទឹក និងប្រព័ន្ធស្រោចស្រព មានការគ្រប់គ្រងប្រកបដោយតម្លាភាព ការចូលរួម សមធម៌ និងការទទួលខុសត្រូវ។
- លើកទឹកចិត្តស្ត្រី ឲ្យចូលរួមក្នុងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងពង្រីកប្រព័ន្ធស្រោចស្រព ដើម្បីធានាឲ្យមានទឹក, ការកាត់បន្ថយភាពតានតឹងផ្នែកទឹក និងទំនាស់លើការប្រើប្រាស់ទឹកដែលផុសចេញពីការខ្សត់ទឹក, និងការគ្រប់គ្រងលើទឹកជំនន់។

## កែលំអការបញ្ជ្រាបយេនឌ័រ

- បង្កើតគោលនយោបាយ និងគោលការណ៍ណែនាំដ៏សមស្របដែលអាចឲ្យស្ត្រី និងបុរស (ក្មេងស្រី និងក្មេងប្រុស) មាន

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

ឱកាសស្មើគ្នាក្នុងការបែងចែក និងគ្រប់គ្រងធនធាន និងក្នុងការចែករំលែកទស្សនៈ និងកង្វល់ក្នុងការសម្រេចចិត្ត។

- លើកកម្ពស់ការគិតគូរពីយេនឌ័រ នៅតាមវិស័យទាំងឡាយ ដើម្បីផ្តល់ឲ្យស្ត្រីនូវការអប់រំ ជំនាញ និងសមត្ថភាពចាំបាច់សម្រាប់ចូលរួមក្នុងលក្ខណៈស្មើភាពគ្នាជាមួយបុរស។
- ផ្តល់ឱកាសស្មើគ្នាដល់បុរស និងស្ត្រីក្នុងការត្រួតត្រាលើធនធានសម្រាប់ចិញ្ចឹមជីវិត, ការបញ្ចេញសំឡេង និងការដោះស្រាយបញ្ហាប្រឈមឲ្យពួកគេ។ ជាពិសេស គួរយកចិត្តទុកដាក់ បង្កើតយុទ្ធសាស្ត្រសមភាពយេនឌ័រគ្រប់ជ្រុងជ្រោយមួយដែលធានាថា បុរស និងស្ត្រីមានឱកាសស្មើគ្នាខាងផ្នែកសង្គម សេដ្ឋកិច្ច ការសម្រេចចិត្ត និងនយោបាយ។
- ពង្រឹងកិច្ចសហការក្នុងចំណោមស្ថាប័នរដ្ឋ ឯកជន និងអង្គការសង្គមស៊ីវិល ដើម្បីពិនិត្យឡើងវិញ និងកែទម្រង់រចនាសម្ព័ន្ធមានស្រាប់ដែលមិនស្មើភាពគ្នានៅក្នុង សកបទ និងបណ្តាក្រុមការងារសង្គមនៅតាមមូលដ្ឋាន។ គួរបង្កើតយុទ្ធសាស្ត្រជាក់ស្តែង និងលើកទឹកចិត្តប្រជាជនឲ្យពង្រឹង ឬបង្កើតសមភាពយេនឌ័រ ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅព្រមទាំងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

## ជំរុញការចូលរួមរបស់ស្ត្រី

- ផ្តល់លទ្ធភាពស្មើគ្នាដល់ស្ត្រីនៅតាមជនបទ ក្នុងការប្រើប្រាស់ និងត្រួតត្រាលើធនធានទ្រព្យរួម ព្រោះជីវភាពរបស់ពួកគេពឹងផ្អែកជាចម្បងទៅលើធនធានទាំងនោះ។ សម្រាប់ស្ត្រីដែលធ្វើការនៅក្នុង សកបទ នោះ ខាងអាជ្ញាធរមូលដ្ឋាន ក្រសួងមន្ទីរថ្នាក់ជាតិនិងថ្នាក់ខេត្ត និងក្រុមការងារសង្គមដទៃទៀតគួរពិចារណាដោយយកចិត្តទុកដាក់ លើការផ្តល់ឱកាសសមស្របសម្រាប់ឲ្យពួកគេបានចូលរួម និងអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្នុងតួនាទីដឹកនាំ និងក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។
- បង្កើនលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបានជំនាញវិជ្ជាជីវៈ និងការបណ្តុះបណ្តាលភ្ជាប់នឹងការងារ (ផ្អែកលើតម្រូវការជាក់ស្តែង និងជាយុទ្ធសាស្ត្រ) និងក្នុងការចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព សម្រាប់បង្កើនផលិតកម្ម និងពិពិធកម្មកសិកម្ម, ការគ្រប់គ្រង កិច្ចដំណើរការ និងការថែទាំប្រព័ន្ធស្រោចស្រព, សមភាពយេនឌ័រ, ការគ្រប់គ្រងគ្រោះមហន្តរាយ, និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។
- លើកទឹកចិត្តស្ត្រីដែលមានសមត្ថភាពខ្ពស់ ឲ្យចែករំលែកបទពិសោធន៍ ជំនាញ និងព័ត៌មាន ដើម្បីជួយបង្កើនសិទ្ធិអំណាច និងពង្រីកចំណេះដឹងនិងសមត្ថភាពរបស់ស្ត្រីដទៃទៀត។
- ដាក់បញ្ចូលគោលការណ៍សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីទៅក្នុងគ្រប់វិស័យ ព្រមទាំងធ្វើការត្រួតពិនិត្យជាទៀងទាត់លើកម្មវិធីអភិវឌ្ឍន៍ផ្នែកទឹក និងការស្រោចស្រព និងកម្មវិធីបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាឲ្យមានការគិតគូរយ៉ាងយកចិត្តទុកដាក់ ពីបញ្ហាផ្នែកយេនឌ័រ និងការជួយទ្រទ្រង់ដល់ជនក្រីក្រ។

## ឯកសារយោង

MOWRAM – Ministry of Water Resources and Meteorology (2005), *Cambodia IWRM Strategy and Road Map*, http://www.gwpsea.org/index.php?option=com_docman&task=doc_download&gid=5&Itemid=135 (accessed 2 January 2013)

MOWRAM (2007), *Law on Water Resources Management of the Kingdom of Cambodia* (Phnom Penh: MOWRAM)

Nang Phirun and Ouch Chhuong (2014), *Gender and Water Governance: Women's Role in Irrigation Management and Development in the Context of Climate Change*, CDRI Working Paper Series No. 89 (Phnom Penh: CDRI)

WEN, Women's Environmental Network (2010), *Gender and The Climate Change Agenda: The Impacts of Climate Change on Women and Public Policy*, http://www.wen.org.uk/wp-content/uploads/Gender-and-the-climate-change-agenda-21.pdf (accessed 6 May 2012)

ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ទេ។